**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រៃវែង**

លេខ: ០៤៧/១៦ [illegible]

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសអ្នកបើកបរ

ផែនការអនុវត្តរយៈបីឆ្នាំដំបូង(ផ.អ៣២០១០-២០១៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០១១ និងបានទទួលការឯកភាពពីគ.ជ.អ.ប ពន្យារពេល១ឆ្នាំទៀត ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់បញ្ចប់ការងារដែលនៅសេសសល់ និងត្រៀមលក្ខណៈសម្រាប់រៀបចំផែនការអនុវត្តរយៈពេល៣ឆ្នាំបន្ទាប់។ ក្នុងអំឡុងពេល៣ឆ្នាំនៃការអនុវត្តនេះរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួលឡើងវិញស្របតាមគោលការណ៍អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។ ជាមួយគ្នានេះ មន្ត្រីរាជការទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធដែលបានកែសម្រួលឡើងវិញផងដែរ។ ក្រៅពីនេះ ច្បាប់ លិខិតបទដ្ឋាន និងសេចក្តីណែនាំចាំបាច់នានាក៏ត្រូវបានរៀបចំ និងដាក់ឲ្យប្រើប្រាស់ ព្រមទាំងការណែនាំតម្រង់ទិស ការបណ្តុះបណ្តាលនិងសកម្មភាពអភិវឌ្ឍសមត្ថភាពនានាអំពីច្បាប់ លិខិតបទដ្ឋាន និងសេចក្តីណែនាំទាំងនោះដល់មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានអនុវត្តជាបណ្តើរៗ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តការងារតាមប្រព័ន្ធគ្រប់គ្រងក្នុងរបត់ថ្មីនៃកំណែទម្រង់។

ក្នុងឆ្នាំកន្លងមកនេះ មូលនិធិក្រុង ស្រុក ខណ្ឌ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ ត្រូវបានដាក់ឲ្យដំណើរការដែលការគ្រប់គ្រង និងអនុវត្តដោយក្រុមប្រឹក្សា និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ កត្តានេះតម្រូវឱ្យមានការគាំទ្របច្ចេកទេសលើកិច្ចការមួយចំនួនដូចជា៖ កិច្ចការហិរញ្ញវត្ថុ ការរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ការគ្រប់គ្រង ការតាមដាន និងវាយតម្លៃ។ ជាមួយនឹងការគាំទ្រខាងផ្នែកបច្ចេកទេស ការបែងចែក ឬការផ្តល់ធនធានមនុស្សប្រកបដោយសមត្ថភាព និងមានឆន្ទៈបំពេញការងារ និងការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាបាននូវការគាំទ្រដ៏មានប្រសិទ្ធិភាពដល់រដ្ឋបាលឃុំ សង្កាត់ ក៏ជាសកម្មភាពបន្ទាន់ពុំអាចខ្វះបានទាំងពេលបច្ចុប្បន្ន និងទៅអនាគត។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តព្រៃវែង សូមប្រកាសជ្រើសរើសបេក្ខជន សម្រាប់មុខតំណែងដូចខាងក្រោម៖

| មុខតំណែង | ចំនួន | ទីកន្លែងបំពេញការងារ | ប្រាក់ខែ |
|---|---|---|---|
| អ្នកបើកបរ | ១ | សម្រាប់ថ្នាក់ខេត្ត | ១៥០ដុល្លា |

តួនាទី និងការកិច្ចទទួលខុសត្រូវលម្អិត (TOR) និងតម្រូវការគុណសម្បត្តិសម្រាប់មុខតំណែងខាងលើ ព្រមទាំងពាក្យសុំបម្រើការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប អាចរកបាននៅសាលាខេត្ត ក្រុង ស្រុកសាមីនីមួយៗ និងមាននៅលើគេហទំព័ររបស់គ.ជ.អ.ប (http://www.ncdd.gov.kh/procurementjobs) និងមានបិទផ្សាយនៅលើក្តារព័ត៌មានសាលាខេត្ត ក្រុង ស្រុក សាមី។

បេក្ខជន បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមផ្ញើលិខិតដាក់ពាក្យសុំ និងប្រវត្តិរូបសង្ខេប (រាប់បញ្ចូលទាំងពាក្យសុំបម្រើការងាររបស់ គ.ជ.អ.ប) ដោយមានបញ្ជាក់ព័ត៌មានសម្រាប់ទំនាក់ទំនង (រួមមាន៖ អាសយដ្ឋាន លេខ

ទូរស័ព្ទ ឬអ៊ីម៉ែល) មកកាន់ផ្នែកគ្រប់គ្រងបុគ្គលិកនៃទីចាត់ការគ្រប់គ្រងធនធានមនុស្សរបស់សាលាខេត្តព្រៃវែងនៅគ្រប់ម៉ោងធ្វើការ ឬតាមរយៈសារអេឡិចត្រូនិច (អ៊ីម៉ែល) pheounpheap@gmail.com ។

ស្ត្រីត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យសម្រាប់មុខតំណែងនេះ
ថ្ងៃឈប់ទទួលពាក្យៈ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ ។
មានតែបេក្ខជនដែលមានឈ្មោះក្នុងបញ្ជីសម្រាំងបេក្ខជនអាទិភាព (shortlist) ប៉ុណ្ណោះ ដែលនឹងទទួលបានព័ត៌មានអំពីការប្រឡងជ្រើសរើស។

បញ្ជាក់៖

មុខតំណែងនេះជាប្រភេទកិច្ចសន្យា ដូច្នេះបេក្ខជនដែលនឹងត្រូវជ្រើសរើសឱ្យបំពេញការងារ ត្រូវតែមិនមែនជាមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលបេក្ខជនជាមន្ត្រីរាជការស៊ីវិល បេក្ខជននោះត្រូវដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្ស ក្នុងរយៈពេលនៃការបំពេញការងារជាមួយកម្មវិធីជាតិ។

ព្រៃវែង ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៦

**អភិបាលខេត្ត**

**ជា សុមេធី**

ចម្លងជូន:
- លេខាធិការដ្ឋានគ.ជ.អ.ប
- ក្រុមប្រឹក្សាខេត្ត
- ឯកសារ